# Living the Lotus 7

## Buddhism in Everyday Life

2025
VOL. 238




## Rissho Kosei-kai of Taipei Celebrated Its 40th Anniversary on May 3

Living the Lotus
Vol. 238 (July 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

*President's Message*

# សូមអរគុណចំពោះអំណោយជីវិតដ៏ថ្លៃថ្លា

ដោយព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ




## សិក្សារៀនសូត្រពីបទពិសោធន៍អតីតកាល

ប្រទេសជប៉ុនតាំងពីមហាសង្គ្រាមលោកលើកទី២បានបញ្ចប់មកដល់ឆ្នាំនេះ,រយៈពេល៨០ឆ្នាំបានកន្លងទៅហើយ។យើងមិនមានចិត្តអ្វីនឹងនិយាយពីរឿងត្រូវខុសនៃសង្គ្រាមឡើយគ្រាន់តែថាសោកនាដកម្មដ៏ខ្លោចផ្សាដោយការទម្លាក់គ្រាប់បែកដ៏មហាស្វារ្យមកលើទីក្រុងតូក្យូនិងសង្គ្រាមដ៏សាហាវស៊ីសាច់ហុតឈាមនៅអូគីណាវ៉ាហើយលើសពីនេះទៅទៀតការទម្លាក់គ្រាប់ បែកបរមាណូគឺជាការចងចាំពីសង្គ្រាមដែលមិនអាចពណ៌នាដោយពាក្យសម្ដីឬសំណេរបាន។ក៏ប៉ុន្តែជាមួយនឹងលំហូនៃពេលវេលា ការចងចាំនោះបានហើរពណ៌ទៅសស្លេតបន្តិចម្ដងៗជាហេតុធ្វើឱ្យយើងមានអារម្មណ៍ស្មុគស្មាញ។

ទោះជាយ៉ាងណាក្ដីដោយសារតែបទពិសោធន៍ ចូលទៅពួនក្នុងត្រង់សេពេលឮសម្លេងស៊ីរ៉ែនដែលប្រាប់ពីការមកដល់នៃយន្តហោះទម្លាក់គ្រាប់បែកដែលខ្ញុំព្រះករុណាអាត្មាភាពមានវាមានតិចតួចពេកខ្ញុំព្រះករុណាអាត្មាភាពជាមូលហេតុឱ្យខ្ញុំព្រះករុណាអាត្មាភាពមិនអាចស្រមៃឃើញឬយល់ដឹងពីអារម្មណ៍និងការចងចាំរបស់អ្នកដែលនៅរស់រានមានជីវិតដោយបានគេចផុតពីការទម្លាក់គ្រាប់បែកនិងការប្រយុទ្ធគ្នាបានទេ។ លោកស្រីម៉ូម៉ូហារ៉ាយូកូជាកវីនិពន្ធដែលមានកំណើតនៅកោះអូគីណាវ៉ាបានសរសេរកំណាព្យថា "អ្នកស្លាប់ដោយត្រូវគ្រាប់គរត្រួតលើអ្នកស្លាប់ដោយឆេះរោលរាលនិងអ្នកស្លាប់ដោយអត់ឃ្លាន-សង្គ្រាមក៏បានបញ្ចប់។" "នៅក្នុងហោប៉ៅកូនដែលគេងស្លាប់មានស្ករអំពៅដែលគ្រូចែកឱ្យនៅម៉ោងញ៉ាំនំចំណី" ។

ជប៉ុនបានទៅជាសមរភូមិចម្បាំងរវាងទ័ពជប៉ុននិងទ័ពពួកសម្ព័ន្ធមិត្តដែលដឹកនាំដោយអាមេរិកនិងអង់គ្លេសហើយបានបាត់បង់ជីវិតដ៏មានតម្លៃជាង២០ម៉ឺនជីវិតនៅអូគីណាវ៉ា។សេចក្ដីសោកសង្រេងនិងសេចក្ដីទុក្ខក្នុងនាមជាម្ដាយដែលបាត់បង់កូនប្រុសជាទីស្រឡាញ់ដែលទើបនឹងរៀនដល់ថ្នាក់ទី៨ដោយសារសង្គ្រាមនេះធ្វើឱ្យយើងជាអ្នកអានកំណាព្យអានទៅតឹងទ្រូងស្ទើរតែប្រេះធ្លាយ។

ក៏ប៉ុន្តែខ្ញុំព្រះករុណាអាត្មាភាពគិតថាសំខាន់យើងតោងតែសម្លឹងមើលឱ្យបានត្រឹមត្រូវហើយពិចារណាពីអតីតកាលដ៏សោកសង្រេងនិងឃោរឃៅនេះដើម្បីកសាងអនាគតកាលដ៏ភ្លឺស្វាង។ពីព្រោះថាយើងត្រូវតែបញ្ជូនការចងចាំទៅអនុជន,ធ្វើស្វ័យត្រិះរិះរកចំណុចដែលត្រូវតែរៀនសូត្រហើយគិតសារឡើងវិញឱ្យទុក្ខសោកនោះក្លាយទៅជាប្រាជ្ញាដើម្បីកសាងពិភពដែលល្អជាងមុនសម្រាប់អនុជនជាន់ក្រោយព្រោះមានតែយើងដែលមានភ័ព្វសំណា ងមាន

ជីវិតរស់នៅទេដែលអាចធ្វើបាន។លោកស្រីអ្នកនិពន្ធសូណូ អាយ៉ាកូបានសរសេរនៅក្នុងកាសែតសាំងយេចុះថ្ងៃទី១៣ខែ៨ឆ្នាំ២០១៦ថាការបង្ហា ញសេចក្តីអាក្រក់ឬអំពើបាបដែលមិនជាបើនឹងមើលព្រមទាំងភាពឃោរឃៅចិញ្ចឹមចិត្តមនុស្សធម៌របស់មនុស្ស។

គេអាចនិយាយបានថាអំពើទាំងនេះជាគ្រូបង្រៀនឱ្យធ្វើល្អតាមរយៈការមើលឃើញអំពើបាបរបស់អ្នកដទៃ។នៅពេលដែលយើងក្រឡេកភ្នែកបែរទៅមើលសង្គ្រាមដែលជាគ្រោះកាចឬក៏ជាភាពអកុសលយើងអាចសម្លឹងមកមើលចិត្តអាក្រក់និងចិត្តល្អដែលមាននៅក្នុងខ្លួនយើងហើយព្យាយាមធ្វើយ៉ាងណាកុំឱ្យកំហុសដដែលៗកើតឡើងវិញជាថ្មី។ជាមួយនឹងគ្នានោះដែរចិត្តមេត្តាករុណាក៏បានចម្រើនលូតលាស់។

ពិធីបុណ្យឧទ្ទិសកុសលជូនវិញ្ញាណខន្ធបុព្វការីដែលស្លាប់បាត់ទៅឬអ្នកដែលបានពលីជីវិតក្នុងសង្គ្រាម ពិតហើយថាជាពិធីសម្រាប់លួងលោមព្រលឹងអ្នកស្លាប់ឱ្យបានស្ងប់ស្ងាត់ក៏ប៉ុន្តែក៏ជាឱកាសសម្រាប់ឱ្យយើងមើលទៅក្នុងចិត្តរបស់យើង ជាឱកាសឱ្យយើងទទួលស្គាល់កំហុសរបស់ខ្លួនឯងហើយជាពេលនិងទីកន្លែងសម្រាប់ឱ្យយើងគិតពីអនាគតកាលផងដែរ។

## ចូរបង្កើតបេះដូងភាពសុខដុំរមនាធំ

ព្រះសម្មាសម្ពុទ្ធលោកបានសម្តែងថា ៖ “មនុស្សទាំងឡាយតែងតែភ័យតក់ស្លុតនឹងអំពើហឹង្សា ហើយទាំងអស់គ្នាខ្លាចស្លាប់ពន់ពេក។យើងតោងតែគិតថារូបយើងរូបគេមិនចង់ស្លាប់ទេដូច្នេះមិនត្រូវសម្លាប់ហើយក៏មិនត្រូវប្រើគេឱ្យសម្លាប់មនុស្សជំនួសខ្លួនដែរ” ។
ពោលគឺថាអ្វីដែលយើងខ្លាចហើយភ័យរន្ធត់អ្នកដទៃក៏គេភ័យតក់ស្លុតដែរ។នរណាម្នាក់ក៏ប្រាថ្នាចង់រស់នៅដោយសេចក្តីសុខស្ងប់ស្ងាត់ជារៀងរាល់ថ្ងៃដែរ។

ម្យ៉ាងទៀតរដ្ឋធម្មនុញ្ញជប៉ុនដំបូងគឺរដ្ឋធម្មនុញ្ញ១៧មាត្រាដែលព្រះអង្គម្ចាស់ហ្សូតុគឺលោកសរសេរមានចែងនៅមាត្រាទី១ថា “មនុស្សម្នាក់ៗតោងតែបង្កើតឱ្យមានភាពសុខដុំរមនានិងភាពស្និទ្ធស្នាល ស្មោះស្ម័គ្រនឹងគ្នា” ។គឺជាឃ្លាដ៏ល្បីល្បាញជាខ្លាំង។

ភាពសុខដុំរមនានិងភាពស្និទ្ធស្នាលស្មោះស្ម័គ្រនឹងគ្នានិង “ស្មារតីដៃវ៉ា (មហាសុខដុំរមនា” របស់ជប៉ុនជាស្មារតីដែលជនជាតិជប៉ុនចាត់ទុកថាជា “ដួងព្រលឹង” របស់ជប៉ុនតាំងពីបុរាណកាលមក។ប្រសិនបើយើងយកពាក្យនេះទៅផ្ទៀងផ្ទាត់ជាមួយនឹងព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធយើងនឹងឃើញថានេះជាសេចក្តីប្រាថ្នាឬជាសេចក្តីបំណងពិតនៃមនុស្សជាតិទាំងអស់ដែលរស់នៅលើភពផែនដីនេះ។ដំណើរឆ្ពោះទៅរកសន្តិភាពពិភពលោកគឺមានតែ “ស្មារតីរស់ជាមួយគ្នាដោយសុខដុំរមនា” នេះតែប៉ុណ្ណោះ។

នៅមុននេះខ្ញុំព្រះករុណាអាត្មាភាពបានណែនាំពីករីម៉ូម៉ូហារ៉ាដែលមានទឹកដីកំណើតនៅកោះអូគីណាវ៉ា។នៅកោះនោះគេហៅប្រទេសជប៉ុនដែលក្រៅពីកោះអូគីណាវ៉ាថា “ប្រទេសយ៉ាម៉ាតូ” ។យ៉ាម៉ាតូនេះបើសរសេរជាអក្សរខាន់ជីចិនគឺវាមានទំនាក់ទំនងទៅនឹងឈ្មោះដែលយើងធ្លាប់ហៅប្រទេសជប៉ុននៅក្នុងកំណត់ត្រាប្រវត្តិ សាស្ត្រថាប្រទេស “ដៃវ៉ា” ដែលអាចអានបានថាយ៉ាម៉ាតូមានន័យថាប្រទេសមហាសន្តិភាព (មហាសុខដុំរមនា) នោះឯង។

យើងទាំងអស់គ្នាដែលរស់នៅក្នុងប្រទេសមហាសន្តិភាពតោងតែមានមានះថាបើមិនខំធ្វើឱ្យស្មារតីសន្តិភាពនោះមានប្រសិទ្ធិភាពទេយើងក៏ “មិនអាចសង្ឃឹមថាពិភពលោកនេះនឹងមានសន្តិភាពនាអនាគតកាលដែរ” ។ពិតណាស់ថាប្រសិនបើមិនអាចរក្សានូវភាពសុខដុំរមនានៅក្នុងគ្រួសារហើយរវាងស្វាមី ភរិយា ឪពុកម្តាយនិងកូនតែងតែមានភាពរកាំរកូសនោះយើងក៏មិនអាចនិយាយពីមហាសន្តិភាពទៅកាន់អ្នកដទៃបានដែរ។ដូច្នេះត្រូវដឹងថាភាពសុខដុំរមនាក្នុងគ្រួសារគឺជាចលនាសន្តិភាពដ៏សំខាន់។យើងតោងតែប្រកបជីវភាពដោយសេចក្តីសុខសប្បាយជាមួយគ្នានិងគ្នា។លើសពីនេះទៅទៀតដើម្បីកុំឱ្យប្រវត្តិសាស្ត្រដ៏សោកសង្រេងកើតមានម្តងហើយម្តងទៀតត្រូវព្យាយាមផ្សព្វផ្សាយសេចក្តីបង្រៀនប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធដើម្បីឆ្ពោះទៅរកគោលដៅគឺសេចក្តីសុខដុំរមនានៃពិភពលោក។ចំពោះយើងដែលបានទទួលជីវិតដ៏គួរឱ្យដឹងគុណដោយបានកើតមកជាមនុស្សអ្វីដែលយើងអាចធ្វើបានគឺមានតែមួយចំណុចនេះទេ។



“កូសេ” លេខខែ៧ឆ្នាំ២០២៥

# Rissho Kosei-kai International

## Make Every Encounter Matter



## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

✉ We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp